ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ : 319ប្រក សក

# ប្រ កា ស

## ស្តីពី

## ដែនកំណត់ចំណតនៃជលយាន

**************

## រដ្ឋមន្ត្រី

## ក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ០២ អ.ន.ក្រ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៨៦ ស្តីពីការកំណត់មណ្ឌលអាជីវកម្មកំពង់ផែ ស្វយ័តភ្នំពេញ

-បានឃើញអនុក្រឹត្យលេខ ៥១ អ.ន.ក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ

-បានឃើញអនុក្រឹត្យលេខ ៦៤ អ.ន.ក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រង ទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារ កំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-អនុសញ្ញាអន្តរជាតិស្តីពី សុវត្ថិភាពជីវិតមនុស្សក្នុងនាវាចរណ៍ឆ្នាំ១៩៧៤ និងវិសោធនកម្មនានានៃ អនុសញ្ញានេះ

-ដើម្បីបង្កើន និងពង្រឹងនូវវិធានការគ្រប់គ្រងសន្តិសុខ សុវត្ថិភាពនាវា សន្តិសុខផែ និងរៀបចំសណ្តាប់ធ្នាប់បណ្តាជលយានយន្ត នានា

## សម្រេច

**ប្រការ១:** រាល់នាវាពាណិជ្ជកម្ម នាវាទេសចរណ៍ ទាំងអស់ដែលធ្វើការដឹកជញ្ជូនតាមផ្លូវទឹកជាលក្ខណៈអន្តរជាតិ ចូលមកកាន់ព្រះរាជាណាចក្រ កម្ពុជា ត្រូវចូលចតនៅកំពង់ផែអន្តរជាតិភ្នំពេញ ដែលជាផែគោលដៅ ។ ការចូលចតក្រៅពីផែគោលដៅចាំបាច់ត្រូវមានការ អនុញ្ញាតពីកំពង់ផែជាមុន ។

ប្រការ២: ជលយានយន្តក្នុងស្រុក និងអន្តរជាតិ ដែលកំពុងធ្វើអាជីវកម្ម ឬប្រើប្រាស់ផ្ទៃទឹកដែលស្ថិតនៅក្នុងមណ្ឌលអាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញ មានភារកិច្ចបង់ពន្ធតាមប្រកាសអន្តរក្រសួង លេខ ៥៦១ សហវ៌ទរ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ និងសេចក្តីសំរេចលេខ ១១០ សសរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការ ប្រកាសអោយប្រើសេចក្តីកំណត់ការយក ពន្ធ និងថ្លៃឈ្នួលផែ ពីនាវាបរទេស។

ប្រការ៣: កំពង់ផែស្វយ័តភ្នំពេញ ត្រូវមានវិធានការទប់ស្កាត់ចំពោះការប្រព្រឹត្តល្មើសនៃមធ្យោបាយដឹកជញ្ជូន នានារួមមាន ការគេចវេសពុំព្រមចូលចតផែ ឬ ចូលចតផែនានា ដោយគ្មានការអនុញ្ញាត ដែលធ្វើអោយបាត់បង់សណ្តាប់ធ្នាប់ សុវត្ថិភាព សន្តិសុខ និងចំណូលពន្ធផងដែរ ។

ប្រការ៤: នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកដ្ឋានដឹកជញ្ជូន អគ្គនាយកសាធារណការ អគ្គាធិការ អង្គភាពពាក់ព័ន្ធ និងអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ មានភារកិច្ចអនុវត្តការងារតាមខ្លឹមសារប្រកាសនេះអោយមានប្រសិទ្ធិភាព ។

ភ្នំពេញ ថ្ងៃទី 29 ខែ 9 ឆ្នាំ២០០៤

រដ្ឋមន្ត្រី

ស៊ុន ចាន់ថុល

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

  "ដើម្បីជូនជ្រាប"
- សាលាក្រុងភ្នំពេញ
- សាលាខេត្តកណ្តាល
- សាលាខេត្តព្រៃវែង
- សាលាខេត្តកំពង់ចាម
- សាលាខេត្តកំពង់ឆ្នាំង
- សាលាខេត្តសៀមរាប

  "ដើម្បីជ្រាប"
- កំពង់ផែស្វយ័តភ្នំពេញ

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ